# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៣-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៤១ ស្តីពីការតែងតាំងឯកឧត្តម **ជា ឆា** ជាជំនួយការសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ៧៣១៧

០៨-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៤៣ ស្តីពីការតែងតាំងលោកជំទាវ **ជឹង សុភាព** ជាឧកញ៉ា ៧៣១៨


## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ


១០-១១-២០០៦ -អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ៧៣១៩

១០-១១-២០០៦ -អនុក្រឹត្យលេខ ៧០៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៣៣២

១០-១១-២០០៦ -អនុក្រឹត្យលេខ ៧០៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៣៣៥


## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៧-១០-២០០៦ -ប្រកាសលេខ ១០២៥ សហវ.ប្រក ស្តីពីការបង្កើតការិយាល័យសម្របសម្រួលការអភិវឌ្ឍន៍ផ្នែកឯកជន ចំណុះឱ្យនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ៧៣៣៦


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១០-១១-២០០៦ -ប្រកាសអន្តរក្រសួងលេខ ១១២០ ប្រក.បទ.សហវ.ចមព ស្តីពីអាជ្ញាប័ណ្ណសេវាបញ្ជើឆាប់រហ័សអន្តរជាតិ ៧៣៣៨

១០-១១-២០០៦ -ប្រកាសអន្តរក្រសួងលេខ ១១២១ ប្រក.បទ.សហវ.ចមព ស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ក្រុមការងារត្រួតពិនិត្យ និងការងារគ្រប់គ្រង ៧៣៤៥


### ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


១០-១១-២០០៦ -ប្រកាសលេខ ១១៧៨ ឧរថ.កឧ.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន **ជីនមុីយ៉ុង ហ្គាមេន ឌីវេឡុបមេន ខប** បង្កើតរោងចក្រ "បោកគក់ ជ្រលក់ពណ៌ និងបំលែងពណ៌" ដែលមានឈ្មោះថា "ជីនមុីយ៉ុង ហ្គាមេន ឌីវេឡុបមេន ខប" ៧៣៤៨

១០-១១-២០០៦ -ប្រកាសលេខ ១១៧៩ ឧរថ.កឧ.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន **ជីឌីអឹម អ៊ិនធើប្រាយ** បង្កើតសាខារោងចក្រ " បោកគក់សម្លៀកបំពាក់ " ដែលមាន ឈ្មោះថា " ជីឌីអឹម អ៊ិនធើប្រាយ សាខាទី ១ " ៧៣៥០

## ៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៤-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) ស៊ី អេស អ៊ិនធើណេសិនណល សូវីង ម៉ាស៊ីន** ៧៣៥២

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី អិល ស៊ី អមេ ខូ អិលធីឌី** ៧៣៥៤

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ុង ជី គ្រុប ខូ អិលធីឌី** ៧៣៥៦

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាខាក្រុមហ៊ុន " ស្លាំមើជើ អយល៍ ហ្វៀល អ៊ុសធើន "** ៧៣៥៨

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថេ ហ្គោង អ៊ិនដាសស្ទ្រៀល** ៧៣៥៩

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពន្លឺ បន្ទាយស្រី ខនស្ត្រាក់សិន** ៧៣៦១

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វីជេន ស្គួល អហ្វ ប៊ីស៊ីនីស គ្រុប** ៧៣៦៣

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្ព័តនីង ឡាយហ្វ៍ គ្រុប** ៧៣៦៥

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដានី ត្រេឌីង ខូ អិលធីឌី** ៧៣៦៧

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤០៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទិចមីរ ស៊ា អ៊ីមផត អិចផត** ៧៣៦៩

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុវណ្ណសិទ្ធិ** ៧៣៧១

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៤១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី២០ ខែមិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ជា ឆា** ជាជំនួយការសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.០៦១១.៤៦៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០០៦

លេខ : ៤២០ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ស៊ុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៨៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោកជំទាវ **ជឹង សុភាព**

ជា

**ឧកញ៉ា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៦១១.៤៦៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦

លេខ: ៤១៧៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិ ដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០០៦

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ និងគ្រប់គ្រងតំបន់រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ។

**មាត្រា ២ .-**

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ ÷

- ធានាការអភិវឌ្ឍតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារប្រកបដោយចីរភាព និងបរិស្ថាន
- អភិរក្សកេរដំណែលវប្បធម៌ និងធនធានធម្មជាតិ
- ជំរុញការទាក់ទាញទេសចរជាតិ និងអន្តរជាតិ ។

**មាត្រា ៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពលើរាល់តំបន់ការពារតាមប្លង់កំណត់ ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/ ០៤០៦/១៨៣ ចុះ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ។

**មាត្រា ៤ .-**

ការរៀបចំ ចាត់ចែង និងគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ជាសមត្ថកិច្ចរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/ រកត/ ០៦០៦/២៤៨ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ ដោយមានកិច្ចសហការជិតស្និទ្ធ និងជាប្រចាំជាមួយអាជ្ញាធរដែនដី ។/

# ជំពូកទី ២
# ការគ្រប់គ្រង និង ការអភិវឌ្ឍ
## ផ្នែកទី ១
## ការអភិវឌ្ឍតំបន់ប្រាសាទព្រះវិហារ

**មាត្រា ៥ .-**

ក្នុងរាល់កិច្ចអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង ៤ (បួន) អ.ជ.ព.វ ត្រូវ ÷

- រៀបចំនីតិក្រម សម្រាប់ពិនិត្យឡើងវិញ និងអនុម័តគម្រោងអភិវឌ្ឍន៍នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- ធានាថា រាល់គម្រោងអភិវឌ្ឍន៍ ត្រូវបានគិតគូរអំពីផលប៉ះពាល់បរិស្ថាន មានគម្រោងសម្រាប់ជំនួស និងបន្ថយផលប៉ះពាល់អវិជ្ជមានឱ្យមានកម្រិតទាបបំផុត
- បញ្ចូលការវាយតម្លៃ ផលប៉ះពាល់បរិស្ថាន ក្នុងការស្រាវជ្រាវវត្ថុបុរាណ នៅតំបន់ពាក់ព័ន្ធទាំងនោះ
- ធ្វើកំណាយសង្គ្រោះផ្នែកបុរាណវិទ្យា ដើម្បីប្រមូលទិន្នន័យផ្នែកបុរាណវិទ្យា និងវត្ថុបុរាណមករក្សាទុកជាមុនសិន បើជាការចាំបាច់ មុននិងចាប់ផ្តើមដំណើរការអភិវឌ្ឍ ។

**មាត្រា ៦ .-**

ការអភិវឌ្ឍក្នុងរមណីយដ្ឋានមានប្រាសាទក្នុងតំបន់ ១ ត្រូវហាមឃាត់ លើកលែងតែការអភិវឌ្ឍណា ដែលមានសារប្រយោជន៍សម្រាប់កិច្ចការពារ និងការលើកស្ទួយតម្លៃនៃរមណីយដ្ឋាននោះ ។

ការអភិវឌ្ឍក្នុងរមណីយដ្ឋានមានប្រាសាទក្នុងតំបន់ ២ ត្រូវហាមឃាត់ លើកលែងតែការអភិវឌ្ឍណា ដែលមានសារប្រយោជន៍ សម្រាប់កិច្ចការពារ និងការលើកស្ទួយតម្លៃនៃស្ថានីយបុរាណវត្ថុនោះ ។

**មាត្រា ៧ .-**

រាល់កិច្ចអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវកំណត់ប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី ដែលត្រូវបានទទួលការយល់ព្រមពីរាជរដ្ឋាភិបាល ។

រាល់ការអភិវឌ្ឍនៅតាមបណ្តោយព្រំដែន ត្រូវមានការឯកភាពពីគណៈកម្មាធិការចម្រុះកិច្ចការព្រំដែននៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

រាល់ការផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវចេញដោយ អ.ជ.ព.វ ហើយត្រូវគោរពតាម បទប្បញ្ញត្តិនគរូបនីយកម្ម និងសំណង់ ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

រាល់ការចេញប័ណ្ណកម្មសិទ្ធដីធ្លី ស្ថាប័នមានសមត្ថកិច្ចត្រូវមានការឯកភាពពី អ.ជ.ព.វ. ។

**មាត្រា ៨ ._**

រាល់ការអភិវឌ្ឍសំណង់នានាក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវគិតគូរអំពីគុណភាពល្អប្រណិត រចនាប័ទ្មខ្មែរ គួបផ្សំនឹង សម័យទំនើប ដោយលើកទឹកចិត្តការប្រើប្រាស់ជាបឋម នូវសម្ភារៈសំណង់ដែលមាន ក្នុងស្រុក ហើយកម្ពស់សំណង់កម្រិតមិនឱ្យលើសពី ១០ ម៉ែត្រ (ដប់ម៉ែត្រ) គិតពីផ្ទៃដីកម្ពស់សូន្យម៉ែត្រ ដល់ស្នាប ជញ្ជាំង ។

## ផ្នែកទី ២
## អំពីបុរាណវត្ថុវិទ្យា

**មាត្រា ៩ ._**

ក្នុងសកម្មភាពបុរាណវិទ្យា នៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង ៤ អ.ជ.ព.វ ត្រូវ ÷

- រៀបចំកម្មវិធីលំអិត ដើម្បីសម្រង់ព័ត៌មានបុរាណវត្ថុ នៅតំបន់ប្រាសាទព្រះវិហារ
- ធ្វើបញ្ជីសារពើភ័ណ្ឌស្ថានីយបុរាណវត្ថុនៅតំបន់ប្រាសាទព្រះវិហារ ហើយបញ្ចូលបញ្ជីនោះទៅក្នុង ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
- កំណត់លក្ខណៈវិនិច្ឆ័យ ព្រមទាំងកម្មវិធីសម្រាប់សំគាល់ស្ថានីយណាដែលជាចំណុចមានផល ប្រយោជន៍ ផ្នែកបុរាណវិទ្យា នរវិទ្យា ឬ ប្រវត្តិវិទ្យា
- រៀបចំទិសដៅ និងគំរូកិច្ចព្រមព្រៀងសម្រាប់ចាត់ចែង គ្រប់គ្រងស្ថានីយទាំងអស់នោះ ក្នុង គោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា អប់រំ ឬ ទស្សនា
- កំណត់លក្ខណៈវិនិច្ឆ័យព្រមទាំងកម្មវិធី សម្រាប់សំគាល់ទេសភាពវប្បធម៌ត្រូវការពារ
- កំណត់ទិសដៅនយោបាយ ដើម្បីចាត់ចែងគ្រប់គ្រងទេសភាពវប្បធម៌ទាំងអស់នោះ ក្នុងគោល បំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា អប់រំ ឬ ទស្សនា
- ដាក់ឱ្យមានអ្នកយាមល្បាត ដើម្បីថែទាំ និងការពារស្ថានីយនីមួយៗ ។

**មាត្រា ១០ ._**

អ.ជ.ព.វ ត្រូវការពារយ៉ាងមធ្យ័តបរិវេណរមណីយដ្ឋានមានប្រាសាទក្នុងតំបន់ ១ ហើយគ្រប់គ្រង បរិវេណទាំងនោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា អប់រំ ឬ ទស្សនា ។

**មាត្រា ១១ ._**

អ.ជ.ព.វ ត្រូវ ÷

- ការពារយ៉ាងមធ្យ័តស្ថានីយបុរាណវត្ថុទាំងអស់ ព្រមទាំងសំណល់វប្បធម៌ដែលស្ថិតនៅលើដី ឬ ក្រោមដីក្នុងតំបន់ ២

- ត្រួតពិនិត្យ និងគ្រប់គ្រងរាល់សកម្មភាពនានា ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់ អវិជ្ជមាន ដល់ស្ថានីយបុរាណវត្ថុទាំងអស់នោះ ។

## ផ្នែកទី ៣
## ការចាត់ចែងគ្រប់គ្រងទស្សនិកជន

**មាត្រា ១២ .-**

ក្នុងការចាត់ចែងគ្រប់គ្រងទស្សនិកជននៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង ៤ អ.ជ.ព.វ ត្រូវ ÷

- គ្រប់គ្រងការចេញ ចូលរបស់សាធារណជន ដែលមានគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យាក្តី អប់រំក្តី និងទស្សនាក្តី

- អនុវត្តតាមគម្រោង និងទិសដៅច្បាស់លាស់ដោយកម្រិតទាំងពេលវេលាចេញ ចូលទាំងតម្លៃប័ណ្ណទស្សនា ទាំងតម្លៃកំសាន្តផ្សេងៗទៀត ចំពោះរាល់ការចេញ ចូលរបស់ទស្សនិកជន

- ទប់ស្កាត់រាល់សកម្មភាពបង្កការប៉ះពាល់គុណភាពបរិស្ថាន បណ្តាលមកពីទស្សនិកជន និងសាធារណជន ។

**មាត្រា ១៣ .-**

ក្នុងការគ្រប់គ្រងទស្សនិកជនក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវ ÷

- កំណត់ និងរៀបចំការចេញ ចូលទស្សនាតាមបែបបទ

- ដាក់ឱ្យមានជាប្រចាំនូវមន្ត្រីរបស់អាជ្ញាធរជាតិ ដើម្បីផ្តល់ព័ត៌មានណែនាំ ថែរក្សាសន្តិសុខ គុណភាពបរិស្ថាន និងផ្តល់សេវាផ្សេងៗដល់ទស្សនិកជន

- កំណត់តម្លៃប័ណ្ណទស្សនា ដោយមានការពិភាក្សា ឯកភាពជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីប្រមូលចំណូល យកមកថែរក្សា និងចាត់ចែងគ្រប់គ្រងរមណីយដ្ឋាននោះ

- កម្រិតចំនួន និងទំហំក្រុមទស្សនិកជន ដើម្បីរក្សាគុណភាពទស្សនកិច្ច និងដើម្បីងាយស្រួលការពារប្រាង្គប្រាសាទ

- ត្រួតពិនិត្យយ៉ាងហ្មត់ចត់នូវប្រភេទរថយន្តដែលអនុញ្ញាតឱ្យចេញ ចូល កម្រិតល្បឿនបើកបរ កំណត់ពេលវេលាឡើងចុះ និងតម្រូវឱ្យចូលចតនៅទីលានចំណតដែលបានកំណត់ ។

**មាត្រា ១៤ .-**

ក្នុងការគ្រប់គ្រងទស្សនិកជនក្នុងតំបន់ ២ អ.ជ.ព.វ ត្រូវ ÷

- ហាមឃាត់រថយន្តដឹកជញ្ជូនធុនធ្ងន់ឆ្លងកាត់ ដែលគ្មានការអនុញ្ញាតពីអាជ្ញាធរជាតិ លើកលែងតែកំណាត់ផ្លូវចាប់ពីច្រកចេញ ចូលតាថាវ និងផ្លូវតាមរង្វង់ព័ទ្ធជុំវិញតំបន់ ២

- កែលំអផ្លូវចេញ ចូល សម្រាប់អ្នករស់នៅក្នុងតំបន់នោះ ដោយជៀសវាងការប៉ះពាល់រមណីយដ្ឋានប្រាសាទបុរាណ

- កំណត់ទីតាំងទទួលភ្ញៀវ ទស្សនិកជន និងទីលានចំណតនៅក្នុងតំបន់ទ្រនាប់

- បង្កើតឱ្យមានផ្លូវថ្មីៗ វង់ព័ទ្ធជុំវិញរមណីយដ្ឋានប្រាសាទព្រះវិហារ និងបង្វែរផ្លូវទាំងឡាយដែលបណ្ដាល ឱ្យប៉ះពាល់ដល់តំបន់ការពាររមណីយដ្ឋានប្រាសាទ

- រក្សា និងទុកប្រើប្រាស់កំណាត់ផ្លូវចាប់ពីចំណុច F ទៅចំណុច T សម្រាប់ជាសេវាទេសចរណ៍ធ្វើដំណើរដោយថ្មើរជើង ជិះសេះ ជិះដំរី ឬទោចក្រយានយន្ត បន្ទាប់ពីចំណតរថយន្តត្រូវបានរៀបចំហើយ និងផ្លូវបុរាណ GB ឬផ្លូវមួយផ្សេងទៀត ត្រូវបានស្ដារ និងដាក់ឱ្យដំណើរការជាមុនសិន ។

# ផ្នែកទី ៤
# សំណង់ទេសចរណ៍

**មាត្រា ១៥ .-**

គ្រប់ការសាងសង់សំណង់ទេសចរណ៍នៅក្នុងរមណីយដ្ឋានវប្បធម៌ ក្នុងតំបន់ទាំង ៤ ត្រូវមានការអនុញ្ញាតពី អ.ជ.ព.វ និងប្រព្រឹត្តទៅតាមបទបញ្ជារបស់ អ.ជ.ព.វ ។

អ.ជ.ព.វ ត្រូវបង្កើតឱ្យមានមធ្យោបាយដឹកភ្ញៀវទេសចរឡើងចុះភ្នំប្រាសាទព្រះវិហារ ។ ទន្ទឹមនេះ អ.ជ.ព.វ ត្រូវបង្កលក្ខណៈ សម្បត្តិដល់ប្រជាពលរដ្ឋ ដែលមានបំណងចូលរួមក្នុងការដឹកជញ្ជូន ភ្ញៀវទេសចរផងដែរ ។

**មាត្រា ១៦ .-**

រាល់សំណង់ទេសចរណ៍ ក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវ ÷

- អនុញ្ញាតឱ្យមានសំណង់តិចបំផុត ហើយជាសំណង់ស្រាលនិងលាក់ក្នុងព្រៃសម្រាប់ទស្សនិកជន

- កំណត់ទីកន្លែង និងរៀបចំឱ្យមានទីលានចំណតទោចក្រយានយន្ត រថយន្តទេសចរណ៍ធុនតូចឱ្យតិចបំផុត

- រៀបចំកន្លែងឱ្យទស្សនិកជនបានទស្សនាកំណាយខាងបុរាណវិទ្យា និងការងារជួសជុលប្រាសាទដែលនឹងត្រូវអនុវត្ត

-រៀបចំ ជួសជុល កែលំអជណ្ដើរបុរាណក្នុងតំបន់ ២ ដោយរក្សាទុកចំណីដីចម្ងាយ ៥០ (ហាសិប) ម៉ែត្រសងខាង ចាប់ពីអ័ក្សជណ្ដើរ ដើម្បីបើកឱ្យទេសចរប្រើប្រាស់ ។

**មាត្រា ១៧ .-**

រាល់សំណង់ទេសចរណ៍ក្នុងតំបន់ ២ អ.ជ.ព.វ ត្រូវកំណត់ទីកន្លែង និងរៀបចំឱ្យមានទីលានចំណតទោចក្រយានយន្ត រថយន្តទេសចរណ៍ធុនតូច ប៊ីស និងមីនីប៊ីស ។

**មាត្រា ១៨ .-**

ក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវ ÷

- បន្ថយហេតុផលប៉ះពាល់អវិជ្ជមានបណ្តាលមកពីទេសចរណ៍ទៅលើសហគមន៍រស់នៅទីនោះ
- រៀបចំទីកន្លែងតូចៗ និងមជ្ឈមណ្ឌលសិប្បកម្ម ដើម្បីផ្តល់លទ្ធភាពផ្នែកសេដ្ឋកិច្ចដល់អ្នករស់នៅទីនោះ ។

## ផ្នែកទី ៥
## ការបង្ហាញរមណីយដ្ឋានវប្បធម៌

**មាត្រា ១៩ .-**

ក្នុងការបង្ហាញរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង ៤ អ.ជ.ព.វ ត្រូវ ÷

- រៀបចំផែនការ ដើម្បីបង្ហាញបុរាណវិទ្យា នរវិទ្យា ព្រមទាំងតំបន់ការពារធម្មជាតិ និងប្រពៃណីអ្នកស្រុកនៃតំបន់
- បង្កើតមជ្ឈមណ្ឌលព័ត៌មាននៅក្រៅរមណីយដ្ឋានត្រូវការពារដាច់ខាត ដើម្បីផ្តល់ជូនទស្សនិកជននូវការណែនាំស្តីពីបេតិកភណ្ឌប្រាសាទព្រះវិហារ ។

**មាត្រា ២០ .-**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ ត្រូវរៀបចំដំណើរទស្សនកិច្ច ឱ្យមានមគ្គុទ្ទេសក៍ និងដាក់ផ្លាកសញ្ញាបង្ហាញពីរមណីយដ្ឋានដែលមានលក្ខណៈដោយឡែក ដូចជា ពើងតាឌី ការដ្ឋានយកថ្មកសាង ប្រាសាទ និងស្រះបុរាណ ។

**មាត្រា ២១ .-**

ក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវបង្ហាញពីជីវភាពរស់នៅរបស់ប្រជាជនដូចជា ទស្សនីយភាពផ្ទៃករបាំបុរាណ ប្រពៃណី ទំនៀមទម្លាប់ ផលិតកម្មសិប្បកម្ម និងទិដ្ឋភាពពិសេសៗពាក់ព័ន្ធដល់ទីតាំង ពេលវេលាដោយឡែករបស់ភ្នំប្រាសាទព្រះវិហារ ។

## ផ្នែកទី ៦

## ការដ្ឋានយកថ្ម

**មាត្រា ២២ ..**

ការធ្វើអាជីវកម្មយកថ្មនៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង ៤ អ.ជ.ព.រ ត្រូវ ÷

- កំណត់ និងការពារការដ្ឋានជីកយកថ្មបាយក្រៀម និងថ្មភក់នៅក្នុងរមណីយដ្ឋានដែលត្រូវការពារ សម្រាប់យកមកប្រើប្រាស់ក្នុងការជួសជុលបុរាណវត្ថុ និងប្រាង្គប្រាសាទ ក្រោយពីបានធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងបានការអនុញ្ញាតពី អ.ជ.ព.រ រួច

- ហាមឃាត់ការជីកកកាយយកដីឥដ្ឋ និងថ្មក្នុងរមណីយដ្ឋាននានាដែលត្រូវការពារ ដើម្បីយកទៅប្រើប្រាស់ក្នុងការស្ថាបនាផ្លូវ ឬសំណង់ផ្សេងៗទៀត ។

## ផ្នែកទី ៧

## ការចាត់ចែងទឹក

**មាត្រា ២៣ ..**

ក្នុងការចាត់ចែងទឹកនៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ការពារទាំង ៤ អ.ជ.រ.ព ត្រូវ ÷

- ជួសជុលដោយផ្អែកៗនូវរចនាសម្ព័ន្ធធារាសាស្ត្របុរាណ និងចាត់ចែងរបបគ្រប់គ្រងទឹក តាមសំណង់ ធារាសាស្ត្រថ្មី និងមានប្រសិទ្ធភាព

- ជៀសវាងការប្រើបច្ចេកវិទ្យា និងរចនាសម្ព័ន្ធថ្មី ដែលអាចធ្វើឱ្យប៉ះពាល់ដល់សំណង់បុរាណ ។

**មាត្រា ២៤ ..**

ក្នុងតំបន់១ អ.ជ.ព.រ ត្រូវថែរក្សាស្រះបុរាណ អូរធម្មជាតិដែលមានស្រាប់ និងការពារនូវបរិស្ថាន ។

**មាត្រា ២៥ ..**

ក្នុងតំបន់ ២ អ.ជ.ព.រ ត្រូវ ÷

- ថែរក្សាស្រះ អាងស្តុកទឹក និងអូរធម្មជាតិ ដែលមានស្រាប់ និងការពារនូវបរិស្ថាន

- ថែរក្សា នឹងពង្រឹងអាងស្តុកទឹកដែលមានស្រាប់ ដោយបង្កើនគុណភាពទឹកឱ្យបានស្អាត និងមានបរិស្ថានល្អ ។

**មាត្រា ២៦ ..**

ក្នុងតំបន់ ៣ អ.ជ.ព.រ ត្រូវអភិវឌ្ឍធារាសាស្ត្រតូចៗ ដើម្បីបង្កើនផលិតផលកសិកម្ម និងដើម្បីការប្រើប្រាស់ផ្ទាល់របស់អ្នករស់នៅទីនោះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់បុរាណវត្ថុ ។

## ផ្នែកទី ៨
## ការចាត់ចែងគ្រប់គ្រងទេសភាព

**មាត្រា ២៧ .-**

ក្នុងការចាត់ចែងគ្រប់គ្រងទេសភាពនៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំងអស់ អ.ជ.ព.វ ត្រូវ ÷

- ការពារ និងបង្កើនតម្លៃទេសភាពវប្បធម៌គ្រប់ការអភិវឌ្ឍ
- បញ្ចូលទៅក្នុងផែនការ និងសកម្មភាពនៃការចាត់ចែងគ្រប់គ្រងរមណីយដ្ឋាន រាល់គោលនយោបាយ និងទិសដៅសម្រាប់ការចាត់ចែងគ្រប់គ្រងទេសភាព ។

**មាត្រា ២៨ .-**

ក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវ ÷

- រៀបចំបង្ហាញសភាពដើមពិតនៃបុរាណវិទ្យា ដោយរៀបចំទេសភាពឱ្យមានលក្ខណៈសមស្រប តាមបុរាណវិទ្យា
- ចាត់ចែងរៀបចំទេសភាពនៅជុំវិញប្រាសាទ ។

**មាត្រា ២៩ .-**

ក្នុងតំបន់ ២ អ.ជ.ព.វ ត្រូវរក្សា និងបង្កើតព្រៃទ្រនាប់ ។

**មាត្រា ៣០ .-**

ក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវលើកស្ទួយតម្លៃទេសភាព តាមរយៈការបង្កើតសកម្មភាពកសិកម្ម និងការរៀបចំដែនដី ។

## ផ្នែកទី ៩
## ការចាត់ចែងគ្រប់គ្រងធនធានធម្មជាតិ

**មាត្រា ៣១ .-**

រាល់ការចាត់ចែងគ្រប់គ្រងធនធានធម្មជាតិនៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ ១, ២ និង ៣ អ.ជ.ព.វ ត្រូវគ្រប់គ្រងទឹក ព្រៃឈើ និងសត្វព្រៃ ដើម្បីថែរក្សានិងបង្កើនជីវចម្រុះ ។

រាល់ការចាត់ចែង និងគ្រប់គ្រងធនធានធម្មជាតិនៅតំបន់ ៤ ត្រូវអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ៣២ ៈ**

ក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវ ÷

- ថែរក្សា និងដាំឡើងវិញ នូវព្រៃឈើធម្មជាតិ ទឹក និង ដីព្រៃឈើ
- ថែទាំ ដាំដើមឈើនៅជុំវិញប្រាសាទឱ្យបានគង់វង្ស ។ យកចេញដើមឈើដែលប៉ះពាល់ដល់សោភ័ណភាព ឬអាចបំផ្លាញដល់ប្រាង្គប្រាសាទ ។

**មាត្រា ៣៣ ៈ**

ក្នុងតំបន់ ២ និងតំបន់ ៣ អ.ជ.ព.វ ត្រូវ ÷

- បង្កើនសួនរុក្ខជាតិ និងផ្លូវលំតាមដងព្រៃ
- ចាប់ផ្តើមអនុវត្តកម្មវិធីដាំដើមឈើ ដែលមានពូជនៅក្នុងតំបន់នេះ ។

## ផ្នែកទី ១០
## អំពីអ្នករស់នៅតាមតំបន់

**មាត្រា ៣៤ ៈ**

ក្នុងរមណីយដ្ឋានវប្បធម៌ធម្មជាតិ តំបន់ទាំង ៤ អ.ជ.ព.វ ត្រូវផ្តល់អាទិភាពការងារដល់អ្នករស់នៅក្នុងរមណីយដ្ឋានត្រូវការពារក្នុងវិស័យចាត់ចែងគ្រប់គ្រងថែទាំរមណីយដ្ឋាន ។

**មាត្រា ៣៥ ៈ**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ មិនអនុញ្ញាតឱ្យមានភូមិ និងទីប្រជុំជន ។

**មាត្រា ៣៦ ៈ**

ក្នុងតំបន់ ៣ និងតំបន់ ៤ អ.ជ.ព.វ ត្រូវ ÷

- បង្កលក្ខណៈងាយស្រួល ជួយជំរុញ និងឧបត្ថម្ភដល់ប្រជាពលរដ្ឋរស់នៅឱ្យបង្កបង្កើនផលកសិកម្មស្រូវ និងដំណាំផ្លែឈើហូបផ្លែ និងដាំបន្លែបង្ការសម្រាប់បម្រើឱ្យភ្ញៀវទេសចរ ដើម្បីបន្ថយការនាំចូលពីបរទេស និងបង្កើនការងារជូនប្រជាពលរដ្ឋ
- រក្សាទុកការប្រើប្រាស់តាមប្រពៃណីនូវដីស្រែ និងវាលស្មៅសម្រាប់សត្វ ។

## ផ្នែកទី ១១
## អំពីវត្តអារាម

**មាត្រា ៣៧ .-**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ មិនអនុញ្ញាតឱ្យមានវត្ត ឬទីតាំងសាសនាផ្សេងៗ ទេ ។

**មាត្រា ៣៨ .-**

ក្នុងតំបន់ ៣ និងតំបន់ ៤ ការបង្កើតវត្តថ្មីនៅតាមភូមិនានាត្រូវគោរពតាមបទប្បញ្ញត្តិច្បាប់ ។

**មាត្រា ៣៩.-**

មិនអនុញ្ញាតឱ្យស្នាក់អាស្រ័យពេលយប់នៅក្នុងប្រាង្គប្រាសាទព្រះវិហារ ។

## ផ្នែកទី ១២
## អំពីសិប្បកម្ម និង សេវាកម្ម

**មាត្រា ៤០ .-**

មិនអនុញ្ញាតឱ្យមានការអភិវឌ្ឍឧស្សាហកម្ម ឬពាណិជ្ជកម្មក្នុងរមណីយដ្ឋានការពារ នៅតំបន់ ១ តំបន់ ២ និងតំបន់ ៣ លើកលែងតែសិប្បកម្ម ឬ សេវាកម្មមានទ្រង់ទ្រាយតូចៗបម្រើឱ្យវិស័យទេសចរណ៍ចាំបាច់ក្នុងការថែទាំ និងកិច្ចការពារទេសភាព វប្បធម៌ និងតំបន់បម្រុងផ្នែកបុរាណវិទ្យា ។

ត្រូវគ្រប់គ្រងឱ្យបានត្រឹមត្រូវរាល់សំណល់បង្កើតឡើងដោយសិប្បកម្ម និងសេវាកម្ម ។

**មាត្រា ៤១ .-**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ ត្រូវកំណត់ទីតាំង ទំហំ និងចំនួនលក់ដូរវត្ថុទាំងឡាយបម្រើឱ្យទេសចរណ៍ឱ្យតិចបំផុត ។

**មាត្រា ៤២ .-**

ក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវ ÷

- បង្កើត និងបង្កើនរោងសិប្បកម្មនៅក្នុងភូមិដែលមានស្រាប់ ឬក្នុងមជ្ឈមណ្ឌលទទួលទេសចរ
- ជំរុញសិប្បកម្មតូចៗ និងក្នុងការផលិតវត្ថុអនុស្សាវរីយ៍ ។

## ផ្នែកទី ១៣
## អំពីបណ្តាញចរន្តអគ្គិសនី

**មាត្រា ៤៣ .-**

ក្នុងតំបន់ ១ តំបន់ ២ និងតំបន់ ៣ អ.ជ.ព.វ ÷

- ត្រូវបានអនុញ្ញាតឱ្យដាក់បណ្តាញចរន្តអគ្គិសនី ដែលផ្តល់អគ្គិសនីដល់មូលដ្ឋាននោះ ដោយរក្សាសោភ័ណភាពធម្មជាតិ
- គ្រប់គ្រងរាល់ការតុបតែង និងការរៀបចំពិធីផ្សេងៗក្នុងតំបន់ ដែលត្រូវអនុវត្តតាមលក្ខណៈបច្ចេកទេស ។

## ផ្នែកទី ១៤
## ការទាក់ទាញអារម្មណ៍ចំពោះបរិស្ថាន

**មាត្រា ៤៤ .-**

ក្នុងតំបន់ទាំង ៤ អ.ជ.ព.វ ត្រូវផ្តើមអនុវត្តកម្មវិធី ដើម្បីឱ្យមានការទាក់ទាញអារម្មណ៍ប្រជាជនមូលដ្ឋាន និងទស្សនិកជន ចំពោះសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ ធម្មជាតិ និងចំពោះបញ្ហា បរិស្ថាន ។

**មាត្រា ៤៥ .-**

ក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវ ÷

- កំណត់ទីតាំង និងរៀបចំតូបលក់ដូរវត្ថុអនុស្សាវរីយ៍តាមរចនាប័ទ្មខ្មែរ
- កំណត់ទីតាំង និងរៀបចំឱ្យមានបង្គន់អនាម័យ ធុងដាក់សំរាមឱ្យបានត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេស ។

## ផ្នែកទី ១៥
## ការបណ្តុះបណ្តាលធនធានមនុស្ស

**មាត្រា ៤៦ .-**

អ.ជ.ព.វ ត្រូវ ÷

- បណ្តុះបណ្តាលកម្មករសម្រាប់ការដ្ឋានកំណាយ និងការជួសជុល
- បណ្តុះបណ្តាលមគ្គុទ្ទេសក៍ ឆ្មាំឧទ្យាន និងបុគ្គលិកថែទាំ
- បណ្តុះបណ្តាលបុរាណវិទូ ស្ថាបត្យករជួសជុល និងអ្នកប្រកបវិជ្ជាជីវៈផ្សេងៗទៀត ក្នុងផ្នែកចាត់ចែងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ធម្មជាតិ

- យកចិត្តទុកដាក់ដល់ប្រជាពលរដ្ឋក្នុងតំបន់មុនគេ ដើម្បីរក្សានិរន្តរភាព ក្នុងការការពារ និងការអភិវឌ្ឍ បានយូរអង្វែង ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៤៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៧៧០៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៣៧

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចំនួន៥០រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **ថ្លូន** | **សុផល** | ប្រធាននាយកដ្ឋាន អនុវត្តច្បាប់ |
| ២-លោក | **ពឹង** | **ស៊ីទុត្ថា** | អនុប្រធាននាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣-លោក | **ឈូក** | **ស្រេគុំ** | អនុប្រធាននាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ |
| ៤-លោក | **លឹម** | **ឆាង** | អនុប្រធាននាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ |
| ៥-លោក | **ជ័យ** | **ជាតិ** | អនុប្រធាននាយកដ្ឋាន ផែនការ និងបណ្តុះបណ្តាល |
| ៦-លោក | **ខៀវ** | **សុជាតិ** | អនុប្រធាននាយកដ្ឋាន ផែនការ និងបណ្តុះបណ្តាល |
| ៧-លោក | **ហួត** | **សុផល្លី** | អនុប្រធាននាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ |
| ៨-លោក | **នាក់** | **យុទ្ធា** | អនុប្រធាននាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ |
| ៩-លោក | **ដួង** | **ស៊ីនណារ៉ា** | អនុប្រធាននាយកដ្ឋាន អនុវត្តច្បាប់ |
| ១០-លោក | **ឡាយ** | **គឹមលី** | អនុប្រធាននាយកដ្ឋាន អនុវត្តច្បាប់ |
| ១១-លោក | **ឯម** | **ហ៊ីយ** | អនុប្រធាននាយកដ្ឋាន នីតិកម្មអប់រំ បង្ការនិងការពារ |
| ១២-លោក | **ថោង** | **សុគន្ធា** | អនុប្រធាននាយកដ្ឋាន នីតិកម្មអប់រំ បង្ការនិងការពារ |
| ១៣-លោក | **រស់** | **ចិន្តា** | អនុប្រធាននាយកដ្ឋាន ស្រាវជ្រាវ និងត្រួតពិនិត្យ |

| | | | |
|---|---|---|---|
| ១៤-លោក | ខេត | មុនីជាតិ | ជំនួយការឯកឧត្តម អនុប្រធានអចិន្ត្រៃយ៍ អ.ជ.ប.គ.ញ |
| ១៥-លោក | ម៉ែន | ដារី | ជំនួយការឯកឧត្តម អនុប្រធានអចិន្ត្រៃយ៍ អ.ជ.ប.គ.ញ |

ខ_មេដាយប្រាក់ការងារ :

| | | | |
|---|---|---|---|
| ១-លោក | ជៀម | ចាន់សុខា | ប្រធានការិយាល័យសរុប នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ២-លោក | លី | សំអាត | ប្រធានការិយាល័យបុគ្គលិក នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣-លោក | អ៊ុំ | សំអឿន | ប្រធានការិយាល័យ គណនេយ្យ |
| ៤-លោក | យី | សិទ្ធ | ប្រធានការិយាល័យ នៃនាយកដ្ឋានអនុវត្តច្បាប់ |
| ៥-លោកស្រី | ឈីម | សិទ្ធិបុណ្យរិទ្ធិ | ប្រធានការិយាល័យ នៃមន្ទីរពិសោធន៍គ្រឿងញៀន |
| ៦-លោក | អ៊ុក | ស៊ីដាវន់ | អនុប្រធានការិយាល័យ នីតិកម្ម |

គ_មេដាយសំរឹទ្ធការងារ :

| | | | |
|---|---|---|---|
| ១-លោក | ធី | សោភ័ណ្ឌ | អនុប្រធានការិយាល័យ បុគ្គលិក |
| ២-លោក | ណារំ | ពូន | អនុប្រធានការិយាល័យ បុគ្គលិក |
| ៣-លោក | ឡាយ | សំអឿន | អនុប្រធានការិយាល័យ សរុប |
| ៤-លោក | សួន | ខៀន | អនុប្រធានការិយាល័យ សរុប |
| ៥-លោក | សំ | សារឿន | អនុប្រធានការិយាល័យ រដ្ឋបាល |
| ៦-លោក | ប្រាក់ | សាលីន | អនុប្រធានការិយាល័យ រដ្ឋបាល |
| ៧-លោក | ឈុំ | សារី | អនុប្រធានការិយាល័យ គណនេយ្យ |
| ៨-លោក | ម៉ឺន | រ៉ា | អនុប្រធានការិយាល័យ ភ័ស្តុភារ |
| ៩-លោក | ឃុន | សារ៉េត | អនុប្រធានការិយាល័យ គំរោងផែនការ និងរដ្ឋបាល |
| ១០-លោក | យិន | យឿត | អនុប្រធានការិយាល័យ ផែនការទូទៅ |
| ១១-លោក | ញ៉ៀម | ចំនួរិទ្ធ | អនុប្រធានការិយាល័យ កិច្ចការអាស៊ី |
| ១២-លោក | សំ | ច័ន្ទជួន | អនុប្រធានការិយាល័យ ស៊ើបការណ៍គ្រឿងញៀន |
| ១៣-លោក | ហេង | ច័ន្ទដារ៉ា | អនុប្រធានការិយាល័យ បណ្តុះបណ្តាល |
| ១៤-លោក | ស៊្រុំ | មុនី | អនុប្រធានការិយាល័យ បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ |
| ១៥-លោក | សុខ | សំអឿន | អនុប្រធានការិយាល័យ បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ |
| ១៦-លោក | ម៉ៃ | សុភ័ក្ត្រ | អនុប្រធានការិយាល័យ ស្រាវជ្រាវសារធាតុញៀន |
| ១៧-លោក | ជិន | សាម៉ុន | អនុប្រធានការិយាល័យ គ្រប់គ្រងឱសថ |
| ១៨-លោក | ពេជ្រ | សុរិយា | អនុប្រធានការិយាល័យ នីតិកម្ម |
| ១៩-លោកស្រី | ពេជ្រ | ចិន្តា | មន្ត្រីការិយាល័យ ភ័ស្តុភារ នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ២០-លោក | ជុន | ហុងពាន | មន្ត្រីនាយកដ្ឋាន នីតិកម្មអប់រំ បង្ការនិងការពារ |
| ២១-លោក | ឃ្លាំង | ស៊ីថន | មន្ត្រីនាយកដ្ឋាន អនុវត្តច្បាប់ |
| ២២-លោក | ជុន | ថាវឿត | មន្ត្រីនាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ |
| ២៣-លោក | សម | សុខវីរៈ | មន្ត្រី មន្ទីរពិសោធន៍ |
| ២៤-លោកស្រី | លេង | សុភាព | មន្ត្រី មន្ទីរពិសោធន៍ |
| ២៥-លោក | ញ៉ៀម | សុវ៉ែនឡា | មន្ត្រី នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យ |

| | | | |
|---|---|---|---|
| ២៦-លោក | ជួន | សុធី | មន្ត្រី នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យ |
| ២៧-លោក | ជាតិ | សុទិដ្ឋា | មន្ត្រី នាយកដ្ឋាន ផែនការ និងបណ្តុះបណ្តាល |
| ២៨-លោក | ឆេព | ពន្លឺ | មន្ត្រី នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ |
| ២៩-លោកស្រី | គុំ | ម៉ារ៉ាភានី | មន្ត្រី នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវអនុវត្ត អនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែវិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧២០.១២.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៣៧

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីអប់រំខេត្តពោធិសាត់ ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការជាមួយ *អង្គការន័រវែស្សសង្គ្រោះកុមារកម្ពុជា* ដើម្បីអភិវឌ្ឍន៍វិស័យអប់រំ ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-លោក | **ម៉ោល អាន** | អនុប្រធានគ្រប់គ្រងគម្រោង |
| ២-លោក | **កែវ យ៉ុង** | អនុប្រធានគ្រប់គ្រងគម្រោង |
| ៣-លោក | **ឡៅ គន** | មន្ត្រីបច្ចេកទេសទទួលបន្ទុកការងារអប់រំក្រៅប្រព័ន្ធ |
| ៤-លោកស្រី | **គឹម ស៊ាន** | មន្ត្រីបច្ចេកទេសទទួលបន្ទុកការងារមត្តេយ្យនិងអប់រំកុមារតូច |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខៈ ១០២៥ ....សហវ.ប្រក.

# ប្រកាស

## ស្តីពី

## ការបង្កើតការិយាល័យសម្របសម្រួលការអភិវឌ្ឍន៍ផ្នែកឯកជន ចំណុះឱ្យនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៤៦ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតអនុគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាសលេខ ៩៧៥ សហវ ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃការងារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

## សំរេច

ប្រការ ១ : បង្កើតការិយាល័យសម្របសម្រួលការអភិវឌ្ឍន៍ផ្នែកឯកជន ចំណុះឱ្យនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ២ : ការិយាល័យសម្របសម្រួលការអភិវឌ្ឍន៍ផ្នែកឯកជន ជាសេនាធិការអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកិច្ចការដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ផ្នែកឯកជន ដែលមានភារកិច្ចដូចតទៅ ÷

- ជាលេខាធិការដ្ឋានក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច (ក្រុម "ឃ") និងអនុគណៈកម្មការបរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ។
- ជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំរាប់កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ផ្នែកឯកជន អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ពាក់ព័ន្ធនឹងការជំរុញវិនិយោគ ការកែលំអបរិស្ថានវិនិយោគនិងធុរកិច្ច និង ការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម។
- ចូលរួមក្នុងដំណើរការអនុម័តគំរោង និងតាមដានការអនុវត្តន៍គំរោងពាក់ព័ន្ធនឹងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ។
- ចូលរួមក្នុងកិច្ចប្រជុំច្រកចេញ-ចូលតែមួយ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។
- បំពេញភារកិច្ចផ្សេងទៀត ពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍ផ្នែកឯកជន តាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៤ : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៦

គាត ឈន់

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន "ដើម្បីជូនជ្រាបជាពត៌មាន"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ...ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខ: ១១៧០.........ប្រក.បទ.សហវ.ចមព

# ប្រកាសអន្តរក្រសួង

## ស្តីពី

## អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍
- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល
- យោងកំណត់ហេតុអង្គប្រជុំអន្តរក្រសួង ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០៦។

## ស ម្រេ ច

**ប្រការ ១ :** ប្រកាសអន្តរក្រសួងនេះ មានគោលដៅគ្រប់គ្រង និងផ្តល់អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ជូនផ្នែកឯកជន ជារូបវន្តបុគ្គល ឬ នីតិបុគ្គល ធ្វើអាជីវកម្មបម្រើសេវា ទទួល ប្រមូល ដឹកជញ្ជូន និងចែកចាយនូវរាល់ សំបុត្រ កញ្ចប់តូច ឬ កញ្ចប់ធំ ដោយស្របច្បាប់បន្ថែមលើសេវាប្រៃសណីយ៍ដែលស្ថិតក្រោមអាជីវកម្មរបស់រដ្ឋ ដើម្បីជួយបំពេញសេវាប្រៃសណីយ៍ និងបម្រើតាមសំណូមពររបស់ប្រជាពលរដ្ឋ។

**ប្រការ ២ :** និយមន័យ

- អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ជាអាជ្ញាប័ណ្ណដែលក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ផ្តល់ជូនផ្នែកឯកជន ជារូបវន្តបុគ្គល ឬ នីតិបុគ្គល ធ្វើអាជីវកម្មបម្រើសេវា ទទួល ប្រមូល ដឹកជញ្ជូន និង ចែកចាយនូវរាល់ សំបុត្រ កញ្ចប់តូច និងកញ្ចប់ធំ មានទម្ងន់អតិបរមា ៥០ គីឡូក្រាម និងនៅលើបញ្ញើនេះមានសរសេរអាសយដ្ឋានអ្នកផ្ញើ និងអ្នកទទួល ឬ អាសយដ្ឋានអ្នកទទួល ឬ លេខកូដសំគាល់។

- សេវាបញ្ញើឆាប់រហ័ស ជាសេវាកម្មទំនើបមួយ ដែលបានរៀបចំប្រព័ន្ធសេវាមានលក្ខណៈអន្តរជាតិ។ សេវានេះត្រូវមានកំណត់ពេលច្បាស់លាស់ ធានានូវសុវត្ថិភាព អាចជឿទុកចិត្តបាន ចាប់តាំងពី ទទួល ប្រមូល ដឹកជញ្ជូន និងចែកដល់ដៃអ្នកទទួល មានការកត់ត្រាតាមដានដោយប្រព័ន្ធព័ត៌មានវិទ្យាជាប្រចាំ ផ្លាស់ប្តូរទៅតាមទិសដៅ និងមានបញ្ជាក់ពីការផ្ញើ និងទទួល។

- ការដឹកជញ្ជូនបញ្ញើឆាប់រហ័ស គឺជាការដឹកជញ្ជូនពីកន្លែងមួយ ទៅកន្លែងមួយទៀត តាមផ្លូវគោក ផ្លូវទឹក ឬ ផ្លូវអាកាស ដោយប្រើប្រាស់មធ្យោបាយមួយ ឬ ច្រើន។

**ប្រការ ៣ :** គ្មានផ្នែកឯកជន ជារូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ អាចធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដោយគ្មានអាជ្ញាប័ណ្ណ មានសុពលភាពដែលចេញដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ឡើយ។

**ប្រការ ៤ :** ផ្នែកឯកជន ជារូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលអាចធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិបាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម :

- មានសញ្ជាតិខ្មែរ ឬ បរទេស
- មានបទពិសោធន៍ខាងវិស័យប្រៃសណីយ៍ និង/ឬ ដឹកជញ្ជូនបញ្ញើឆាប់រហ័សអន្តរជាតិ
- បានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
- មានទីតាំងសមស្រប និងត្រូវមានឯកសារបញ្ជាក់ច្បាស់លាស់។

**ប្រការ ៥ :** ផ្នែកឯកជន ជារូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងចង់ធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណ នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

**ប្រការ ៦:** ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចរបស់ក្រសួង តម្រូវឱ្យបំពេញបន្ថែមឯកសារចាំបាច់ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតពាក្យសុំ ក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលបានទទួលពាក្យសុំ។

**ប្រការ ៧:** អ្នកកាន់អាជ្ញាប័ណ្ណមិនអាច ជួល លក់ ឬ បញ្ចាំ អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ទៅឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ផ្សេងទៀតបានឡើយ។ ការបោះបង់ ឬ ការផ្ទេរ អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ទៅឱ្យ រូបវន្តបុគ្គល ឬ នីតិបុគ្គល ផ្សេងទៀត អាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ ៨:** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានសិទ្ធិក្នុងការកែសម្រួល ព្យួរ បដិសេធន៍ ឬ ដកហូត អាជ្ញាប័ណ្ណ ក្នុងករណីដូចខាងក្រោម :

ក- ការកែសម្រួលអាជ្ញាប័ណ្ណ ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណ បានជូនព័ត៌មានជាលាយលក្ខណ៍អក្សរអំពីការ:

- ពង្រីកសាខាបន្ថែម
- ប្តូរទីតាំង
- លុបចោលសាខាមួយចំនួន។

ខ- ការព្យួរអាជ្ញាប័ណ្ណ ក្នុងករណី អ្នកកាន់អាជ្ញាប័ណ្ណ :

- ធ្វើអាជីវកម្មខុសពីលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាប័ណ្ណ
- មិនបានអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួនបីលើក ក្រោយពីបានជូនដំណឹងបីដង ក្នុងមួយដងៗមានរយៈពេល១០ថ្ងៃ នៃថ្ងៃធ្វើការ ។ អាជ្ញាប័ណ្ណ នេះនឹងត្រូវព្យួររហូតដល់អស់សុពលភាព បើសិនជាអ្នកកាន់អាជ្ញាប័ណ្ណមិនចូលមកដោះស្រាយ ។
- ត្រូវបានស្ថាប័នមានសមត្ថកិច្ចស្នើសុំឱ្យព្យួរ ដោយមូលហេតុមានការរំលោភលើលិខិតបទដ្ឋានច្បាប់ ជាធរមាន ។

គ- ការបដិសេធន៍ ឬ ដកហូតអាជ្ញាប័ណ្ណក្នុងករណី :

- អាជ្ញាប័ណ្ណអស់សុពលភាពហើយពុំបានស្នើសុំបន្ត
- អាជ្ញាប័ណ្ណត្រូវបានព្យួរ ២ដង ហើយពុំរាងចាល
- អ្នកកាន់អាជ្ញាប័ណ្ណបាន ជួល លក់ ឬ បញ្ចាំ អាជ្ញាប័ណ្ណរបស់ខ្លួនទៅឱ្យ រូបវន្តបុគ្គល ឬ នីតិបុគ្គលផ្សេងទៀត ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- អ្នកកាន់អាជ្ញាប័ណ្ណពុំបានធ្វើសកម្មភាពអាជីវកម្មរយៈពេល៦ខែ ក្រោយពីទទួលបានអាជ្ញាប័ណ្ណ ។

**ប្រការ ៩:** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវជូនដំណឹងដល់អ្នកកាន់អាជ្ញាប័ណ្ណ ជាលាយលក្ខណ៍អក្សរ និងចុះផ្សាយតាមបណ្តាញព័ត៌មាន នូវសេចក្តីសម្រេចរបស់ក្រសួង ចំពោះការបដិសេធន៍ ឬ ដកហូតមកវិញនូវអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ។ អ្នកកាន់អាជ្ញាប័ណ្ណអាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរមកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងរយៈពេល ២៥ថ្ងៃ ចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងតាមបញ្ញើអនុសិដ្ឋរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ ១០:** អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេលតិចបំផុត១ឆ្នាំ និងច្រើនបំផុត១០ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ ក្នុងករណីអាជ្ញាប័ណ្ណអស់សុពលភាព អ្នកកាន់អាជ្ញាប័ណ្ណអាចដាក់ពាក្យសុំបន្តឱ្យបានមុន៣០ថ្ងៃ ។

**ប្រការ ១១:** តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ គណនាតាមសុពលភាពនៃអាជ្ញាប័ណ្ណនីមួយៗដូចតទៅ:

ក- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ១ឆ្នាំ ត្រូវបានកំណត់ ៣០.៧០០.០០០រៀល ។

ខ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ២ឆ្នាំ ត្រូវបានកំណត់ ៥៩.២០០.០០០រៀល ។

គ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៣ឆ្នាំ ត្រូវបានកំណត់ ៨៥.៦០០.០០០រៀល ។

ឃ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៤ឆ្នាំ ត្រូវបានកំណត់ ១០៩.៩០០.០០០រៀល។

ង- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៥ឆ្នាំ ត្រូវបានកំណត់ ១៣២.៦០០.០០០រៀល។

ច- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៦ឆ្នាំ ត្រូវបានកំណត់ ១៥៣.៥០០.០០០រៀល។

ឆ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៧ឆ្នាំ ត្រូវបានកំណត់ ១៧២.៩០០.០០០រៀល។

ជ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៨ឆ្នាំ ត្រូវបានកំណត់ ១៩០.៨០០.០០០រៀល។

ឈ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៩ឆ្នាំ ត្រូវបានកំណត់ ២០៧.៥០០.០០០រៀល។

ញ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ១០ឆ្នាំ ត្រូវបានកំណត់ ២២២.៨០០.០០០រៀល។

តម្លៃអាជ្ញាប័ណ្ណទាំង១០ប្រភេទខាងលើនេះត្រូវបង់ប្រាក់កក់ចំនួន ២.០០០.០០០រៀល នៅពេល ដាក់ពាក្យសុំដំបូង និងបង់បង្គ្រប់នៅពេលទទួលបានគោលការណ៍អនុញ្ញាត ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

ក្នុងករណីស្នើសុំអាជ្ញាប័ណ្ណពុំទទួលបានការអនុញ្ញាត ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រាក់កក់ដំបូងចំនួន ២.០០០.០០០រៀល ត្រូវប្រគល់ជូនអ្នកស្នើសុំវិញ។

ក្នុងករណីអ្នកដាក់ពាក្យ បានបោះបង់ចោលការស្នើសុំអាជ្ញាប័ណ្ណ ក្រោយពេលគោលការណ៍ត្រូវបានអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រាក់កក់ចំនួន ២.០០០.០០០រៀល ត្រូវបង្វែរចូលថវិកាជាតិ។

**ប្រការ ១២:** អ្នកកាន់អាជ្ញាប័ណ្ណចង់ពង្រីកសាខាបន្ថែម ឬ ប្តូរទីតាំង ឬ សុំលុបចោលសាខាមួយចំនួនដែលមានចែងក្នុងអាជ្ញាប័ណ្ណ ត្រូវផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរជាមុន ជូនមកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ ១៣ :** អ្នកកាន់អាជ្ញាប័ណ្ណអាចបម្រើសេវាបញ្ញើប្រៃសណីយ៍តាមយន្តហោះ ដែលមានទម្ងន់ក្រោម៥០០ក្រាមបាន ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណនោះគិតតម្លៃសេវា លើសពី៥ដង នៃតម្លៃសេវាមូលដ្ឋានរបស់រដ្ឋ។

**ប្រការ ១៤:** អ្នកកាន់អាជ្ញាប័ណ្ណ អាចធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិគ្រប់ប្រភេទ លើកលែងតែវត្ថុដែលត្រូវហាមឃាត់ ដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់ស្តីពីវិស័យប្រៃសណីយ៍។

**ប្រការ ១៥:** អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់របាយការណ៍បរិមាណផលិតផលដែលបានធ្វើអាជីវកម្ម ជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀងរាល់ត្រីមាសឱ្យបានទៀងទាត់។ របាយការណ៍នេះត្រូវបានរក្សាការសំងាត់។

**ប្រការ ១៦:** អ្នកកាន់អាជ្ញាប័ណ្ណត្រូវទទួលខុសត្រូវ និងសងចំពោះអ្នកផ្ញើ ឬ អ្នកទទួល ក្នុងករណីមានការបាត់បង់ ឬ ខូចខាតនូវរាល់បញ្ញើឆាប់រហ័សអន្តរជាតិ លើកលែងបញ្ញើត្រូវបានបាត់បង់ ឬ ខូចខាត ដោយករណីប្រធានស័ក្តិ ឬ បញ្ញើដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌត្រូវបានរឹបអូស។ សំណងនេះត្រូវសងរហូតដល់តម្លៃអតិបរមាមួយដែលកំណត់ដោយក្រុមហ៊ុន។

**ប្រការ ១៧:** អ្នកផ្ញើ ឬ អ្នកទទួល មានសិទ្ធិប្តឹងតវ៉ាអំពីបញ្ញើឆាប់រហ័សអន្តរជាតិ ដែលបានបាត់បង់ ឬ ខូចខាតចំពោះអ្នកកាន់អាជ្ញាប័ណ្ណដែលខ្លួនបានផ្ញើ ឬ ទទួលក្នុងអំឡុងពេល ០៦ខែ គិតចាប់ពីថ្ងៃផ្ញើ ឬថ្ងៃទទួលបញ្ញើ។

**ប្រការ ១៨:** នាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានភារកិច្ចគ្រប់គ្រងអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ និងតាមដាននូវរាល់សកម្មភាពរបស់ក្រុមហ៊ុនធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ឱ្យអនុវត្តត្រឹមត្រូវតាមខ្លឹមសារនៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដែលបានផ្តល់ជូន និងតាមច្បាប់ លិខិតបទដ្ឋានដែលមាន ជាធរមាន។

**ប្រការ ១៩:** នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានភារកិច្ចត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដើម្បីកសាងសំណុំឯកសារ នៅពេលមានវិវាទ ឬ បណ្តឹងតវ៉ាផ្សេងៗ។

**ប្រការ ២០:** - អ្នកកាន់អាជ្ញាប័ណ្ណទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងប្រការ ១៤ នៃប្រកាសអន្តរក្រសួងនេះ ត្រូវទទួលពិន័យ និង/ឬ ផ្តន្ទាទោសតាម មាត្រា៤៦ នៃច្បាប់ស្តីពីវិស័យប្រៃសណីយ៍។

- ត្រូវពិន័យជាប្រាក់ពី១.០០០.០០០រៀល ដល់ ១០.០០០.០០០រៀល អ្នកកាន់អាជ្ញាប័ណ្ណមិនគោរពតាមបញ្ញត្តិ ដូចមានចែងក្នុង ប្រការ១២ នៃប្រកាសអន្តរក្រសួងនេះ។ ករណីមិនរាងចាលត្រូវដកហូតអាជ្ញាប័ណ្ណ ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

- ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០រៀល ដល់ ១០.០០០.០០០រៀល ចំពោះជនណាដែលធ្វើអាជីវកម្មបម្រើសេវាទទួល ប្រមូល ដឹកជញ្ជូន និងចែកចាយបញ្ញើឆាប់រហ័សអន្តរជាតិ ដោយគ្មានអាជ្ញាប័ណ្ណ ដូចមានចែងក្នុងប្រការ៣ នៃប្រកាសអន្តរក្រសួងនេះ ហើយត្រូវបញ្ឈប់អាជីវកម្មខុសច្បាប់នេះជាបន្ទាន់ ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ករណីមិនរាងចាលត្រូវបញ្ជូនសំណុំរឿងទៅតុលាការ។

- អ្នកកាន់អាជ្ញាប័ណ្ណ មិនគោរពតាមបញ្ញត្តិដូចមានចែងក្នុងប្រការ៧ នៃប្រកាសអន្តរក្រសួងនេះ ត្រូវពិន័យជាប្រាក់ ពី ៥.០០០.០០០រៀល ដល់ ២០.០០០.០០០រៀល ហើយត្រូវដកហូតអាជ្ញាប័ណ្ណ។

**ប្រការ ២១**: រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃប្រកាសអន្តរក្រសួងនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២២**: អគ្គនាយកដ្ឋាន នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- គ្រប់សាលាខេត្តក្រុង
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២២
  "ដើម្បីមុខការ"
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ "...ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព"
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ: ១១៩១.........ប្រក.បទ.សហវ.ចមព

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការផ្តល់ប្រាក់ឧបត្ថមសម្រាប់
# ក្រុមការងារត្រួតពិនិត្យនិងការងារគ្រប់គ្រង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
